ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ១៧៥១ អយក.ប្រក

# ប្រកាស

## ស្តីពីការទទួលស្គាល់សាខាវិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច នៅខេត្តបន្ទាយមានជ័យ

+++++

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង អប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពី ការបង្កើតវិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច
- បានឃើញសារាចរណែនាំលេខ ០៦ អយក.សរណន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការបើកឯកទេសថ្មី ដេប៉ាតឺម៉ង់ថ្មី មហាវិទ្យាល័យថ្មី ថ្នាក់ថ្មី និង ការបើកសាខា នៅតាមគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញ លិខិតលេខ ៤៥៥-៤៣ វគស ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៤ និងលេខ ០០១-៤៣ វគស ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៤ របស់វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច
- បានឃើញយោបល់របស់អគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ

Email: crsmeys@camnet.com.kh Web Site www.moeys.gov.kh

## សំរេច

**ប្រការ ១** : ទទួលស្គាល់ការបង្កើតសាខាវិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច ដែលមានទីតាំងស្ថិតនៅ ភូមិគោរដ្ឋាន ឃុំអូរអំពិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**ប្រការ ២** : ក្នុងដំណើរការចាប់ផ្តើម សាខានេះ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្ររង ដែលមានឯកទេស គ្រប់គ្រង ទីផ្សារ គណនេយ្យ ព័ត៌មានវិទ្យា និងថ្នាក់បរិញ្ញាប័ត្រ ដែលមានឯកទេស គ្រប់គ្រង គណនេយ្យ ទីផ្សារ និង សេដ្ឋកិច្ច ។

ទៅអនាគត សាខានេះ អាចធ្វើការបណ្តុះបណ្តាល លើឯកទេស ដទៃទៀត តាមការិត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួង អប់រំ យុវជន និងកីឡា ។

**ប្រការ ៣** : នាយក វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាខានេះ និងធានាសុវត្ថិភាព-សណ្តាប់ធ្នាប់ក្នុងសង្គម ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសាខា ដោយចាត់តាំងអោយមាន នាយកប្រតិបត្តិមួយរូប ទទួលបន្ទុករួម ។
- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជននិងកីឡាដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ និងធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា តាមការកំណត់ ។

**ប្រការ ៤** : ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិត្រួតពិនិត្យ លើគុណភាពបណ្តុះបណ្តាល និង មានសិទ្ធិបិទសាខានេះ ប្រសិនបើសាខា អនុវត្តខុសពីបទដ្ឋានកំណត់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៥** : និស្សិតដែលរៀនចប់កម្មវិធីសិក្សានិងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមការិតនិងតាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ត្រូវបានផ្តល់អោយ ដោយវិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជននិងកីឡា ក្នុងករណីសាខានេះ បំពេញនិងអនុវត្តបានតាមគោលការណ៍កំណត់របស់ក្រសួង អប់រំ យុវជន និងកីឡា ។

**ប្រការ ៦** : អគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេសនិងវិជ្ជាជីវៈ នាយកដ្ឋានឧត្តមសិក្សា វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច និង អង្គភាពពាក់ព័ន្ធ មានភារកិច្ចរៀងៗខ្លួន អនុវត្តនិងប្រតិបត្តិតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ ២០០៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត កុល ផេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី. -សាលាខេត្តបន្ទាយមានជ័យ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំយុវជននិងកីឡា
- មន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ . -ឯកសារ ន.ឧស